# "ចាប់ត្រីត្រពាំងរូម" តាមទម្លាប់អ្នកស្រុកតំបន់អង្គរ

តាមចំណាំទំនៀមអ្នកស្រុកតំបន់អង្គរ បន្ទាប់ពីប្រមូលផលស្រូវរួចរាល់គេតែងចាប់ផ្ដើមរៀបចំកិច្ចឬពិធី តូចឬធំ នៅក្នុងភូមិឬតាមផ្ទះរៀងៗខ្លួន ចាប់ពីខែមាឃឬហៅម្យ៉ាងទៀតថាមាឃធំ។ ពិធីដែលឃើញប្រារព្ធស្ទើរគ្រប់ភូមិនាដើមខែនោះគឺ "ពិធីឡើងមាឃ" ឬ "៣កើតមាឃធំ"។[1] ពិធីនេះហាក់ដូចជាសញ្ញាថាវដ្តនៃរដូវធ្វើស្រែបានបញ្ចប់ ហើយដែលអ្នកស្រុកតែងសាទរភោគផលផ្សេងៗ ជាពិសេសគឺផល "ស្រូវ" ដោយរៀបចំពិធីឡើងមាឃ ឬពូនភ្នំស្រូវ ឬឡើងអ្នកតា។ ដើម្បីដំណើរការនៃទំនៀមទាំងនេះ អ្នកស្រុកតំបន់អង្គរនៅរក្សាទម្លាប់តជាប់មកតាមចំណាំគឺ "ចាប់ត្រីក្នុងត្រពាំងរូម" នៅក្នុងភូមិសម្រាប់ចាត់ចែងជាម្ហូបអាហារ ឱ្យសម្បូរសប្បាយក្នុងដំណើរពិធីតាំងពីដើមរហូតចប់ ដូចរៀបរាប់ខាងលើ ហើយដែលជួនកាលនៅក្នុងភូមិខ្លះគេនាំគ្នាខ្វាយខ្វល់ ចាត់ចែងរៀបចំចង្ហាន់ប្រគេនព្រះសង្ឃផងហៅថា "ឆាន់ឡើងមាឃ" (រូបលេខ១-២)។ ចំពោះទម្លាប់ចាប់ត្រីក្នុងត្រពាំងរូម គេមានឃើញច្រើនភូមិគួរសមដែរនៅជុំវិញតំបន់អង្គរ តែក្នុងអត្ថបទនេះខ្ញុំលើកបង្ហាញនៅភូមិបង្កោង និងភូមិក្បាលដំរី ក្នុងខេត្តសៀមរាប ដែលខ្ញុំធ្លាប់បានឃើញដោយផ្ទាល់ភ្នែក និងបានជជែកសួរនាំអ្នកស្រុកខ្លះៗទុកជាការស្វែងយល់។



រូបលេខ១ កិច្ចប្រុងពាលីរៀបចំប្រារព្ធបុណ្យឡើងមាឃនៅក្នុងភូមិបង្កោង



រូបលេខ២ អ្នកភូមិរៀបចំចង្ហាន់ប្រគេនព្រះសង្ឃក្នុងពិធីបុណ្យឡើងមាឃនៅក្នុងភូមិបង្កោង

[1] សូមអានលម្អិត៖ "៣កើត មាឃធំ" ដោយ អាំង ជូលាន, ២០១២-២០១៣: ៤៣-៣៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ភូមិបង្កោង ស្ថិតនៅភាគខាងកើតតំបន់អង្គរ នៅក្នុងឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប ហើយបច្ចុប្បន្នគេស្គាល់ភូមិនេះច្បាស់ ដ្បិតមានការផ្សព្វផ្សាយអំពីទំនៀមចាប់ត្រីក្នុងត្រពាំងរួមគ្នាយ៉ាងល្បីល្បាញលើបណ្តាញសង្គម។ ប៉ុន្តែនៅក្នុងក្រសែភ្នែកអ្នកស្រាវជ្រាវ គេយល់ថាបង្កោងជាភូមិបុរាណ ដោយមានការលើកឡើងពីសិលាចារឹកស.វ. ទី៩ នៅតំបន់រលួសមានពាក្យ "វកោង"។ លើសពីនោះគេឃើញមានតឹកតាំងសំណល់ឡកុលាលភាជន៍សម័យបុរាណនៅជុំវិញតំបន់នោះផង។[2] មិនតែប៉ុណ្ណោះ ត្រពាំងដែលអ្នកភូមិតែងចាប់ត្រីរួមគ្នានោះឈ្មោះថា "ត្រពាំងបឹង" ឬពីមុនអ្នកខ្លះហៅថា"ត្រពាំងសារាយ"[3] មានខ្ទមអ្នកតាខាងកើតមាត់ត្រពាំងឈ្មោះ"អ្នកតាប្រសិទ្ធផ្ទ(ឬអ្នកតាបឹង)"(រូបលេខ២៤) និង "អ្នកតាដេកផ្សារ" ដែលជាថ្មគោលមានឆ្លាក់រូបព្រះពុទ្ធទាំងបួនជ្រុង(រូបលេខ២៥) ស្ថិតនៅក្នុងទឹកត្រពាំងសព្វថ្ងៃ។




រូបលេខ២៣ អ្នកភូមិបង្កោងនាំគ្នាចុះចាប់ត្រីក្នុងត្រពាំងបឹង

---

[2] ខៀវ ច័ន្ទ, ២០១៣-២០១៤: ៣៨-៤៣, និង ធាន់ សុភីនី និងសហសេវិក, ២០២១: ១៨៦

[3] អាំង ជូលាន, ២០២០: ២៣២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៤ ខ្ទមអ្នកតាបឹង ឬអ្នកតាប្រសិទ្ធ



រូបលេខ២៥ អ្នកតាដេកផ្ងារ

ដូចបានបញ្ជាក់ខាងដើមស្រេចមកថា ទម្លាប់ចាប់ត្រីនៅក្នុងត្រពាំងបឹងនេះ គឺដើម្បីយកទៅរៀបចំចាត់ចែងធ្វើបុណ្យឡើងមាឃ។ ប៉ុន្តែចំពោះពិធីឡើងមាឃនៅភូមិបង្កោងពុំកំណត់យកថ្ងៃជាក់លាក់ ឬយកចំថ្ងៃ៣កើត ខែមាឃ ដូចភូមិដទៃទេ ដ្បិតមានហេតុផលខ្លះបញ្ជាក់ថា អាស្រ័យលើការមូលមាត់ក្នុងភូមិ និងអាស្រ័យលើទឹកត្រពាំងស្រកអាចចុះចាប់ត្រីបានឬអត់ តែពុំដែលរំលងហួសដាច់ខែមាឃឡើយ។[4] ជាច្បាប់ទម្លាប់ផ្ទៃក្នុង អ្នកភូមិមូលមាត់កំណត់គ្នាចាប់ពីខែទឹកឡើងរហូតមកដល់មុនថ្ងៃឡើងមាឃ គឺក្នុងរយៈពេលប៉ុន្មានខែនេះ គ្មាននរណាមានសិទ្ធិរកត្រីទាំងអស់នៅក្នុងត្រពាំងនោះ។[5] លុះដល់មុនថ្ងៃប្រារព្ធពិធីមួយថ្ងៃ អ្នកភូមិនាំគ្នាក្រោកពីព្រលឹមស្រាងៗ ទៅជួបជុំគ្នានៅមាត់ត្រពាំងរង់ចាំស្តាប់សញ្ញាដែលមេភូមិអនុញ្ញាតឲ្យចុះចាប់ត្រី (រូបលេខ២៦-៧)។



រូបលេខ២៦ អ្នកភូមិរង់ចាំសញ្ញាអនុញ្ញាតចុះចាប់ត្រី



រូបលេខ២៧ អ្នកភូមិចុះចាប់ត្រីបន្ទាប់ពីសញ្ញាអនុញ្ញាត

[4] ហៀង ម៉ារ៉ា, ២០២៣: ៤១

[5] អាំង ជូលាន, ២០២០: ២៣២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមទម្លាប់អ្នកភូមិតែងចុះចាប់ត្រីនៅក្នុងត្រពាំងបឹងពេញមួយថ្ងៃ ដើម្បីធ្វើម្ហូប ជាពិសេសធ្វើសម្ល នំបញ្ចុកប្រគេនព្រះសង្ឃក្នុងថ្ងៃបន្ទាប់។ ការចុះចាប់ត្រីនោះ គេអនុញ្ញាតឱ្យតែអ្នកភូមិប៉ុណ្ណោះ អ្នកចម្ងាយពុំអនុញ្ញាតឡើយ ហើយគេឱ្យប្រើតែឧបករណ៍សាមញ្ញមួយចំនួនដូចជា សំណាញ់ មង អង្រុត និងឈ្នាងជាដើម។ ត្រីមួយភាគដែលម្នាក់ៗរកបានគេអនុញ្ញាតឱ្យយកទៅផ្ទះរៀងៗខ្លួន ប៉ុន្តែនៅនាទីចុងក្រោយដែលគេរើសម្រាស់នៅកណ្តាលត្រពាំងនោះ គឺចាប់បានទុកជាត្រីរួមសម្រាប់ចាត់ចែងធ្វើម្ហូបនៅសាលាបុណ្យ។

ដោយឡែកចំពោះទម្លាប់ចាប់ត្រីរបស់អ្នកភូមិក្បាលដំរី ហាក់ពុំមានសភាពគគ្រឹកគគ្រេងដូចភូមិបង្កោងឡើយ។ ភូមិក្បាលដំរី (ឬភូមិសំបួរ) ស្ថិតក្នុងឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។ អ្នកភូមិទាំងនេះតែងចាប់ត្រីក្នុងត្រពាំងរួមប្រចាំភូមិ នៅក្នុងដើមខែមាឃ ឬអាចនិយាយថាចុះចាប់ត្រីមុនភូមិបង្កោង។ នៅភូមិក្បាលដំរី គេចុះចាប់ត្រីក្នុងត្រពាំងរួមឈ្មោះ "ត្រពាំងក្បាលដំរី" ដែលស្ថិតនៅកណ្តាលភូមិ ហើយភាគច្រើនមានតែមនុស្សប្រុសប្រហែល២០ទៅ៣០នាក់ប៉ុណ្ណោះដែលចេញមុខចុះចាប់ត្រីរួម (រូបលេខ២៨)។ ការចាប់ត្រីនេះ ភាគច្រើនគេមូលមាត់គ្នាចុះចាប់ត្រីថ្ងៃ២កើត ខែមាឃ ដើម្បីត្រៀមយកធ្វើម្ហូបក្នុងពិធីឡើងមាឃនៅថ្ងៃទី៣ កើត។ ទំនៀមអ្នកភូមិនេះ ច្រើនធ្វើកិច្ចឡើងមាឃនៅខ្ទមអ្នកតាឈ្មោះ "តាគង់យាយរ័ត្ន" ស្ថិតនៅមាត់ត្រពាំងខាងកើត (រូបលេខ២៩)។



រូបលេខ២៨ អ្នកភូមិចុះចាប់ត្រីត្រពាំងក្បាលដំរី



រូបលេខ២៩ ខ្ទមតាគង់យាយរ័ត្ននៅមាត់ត្រពាំង

កិច្ចឡើងមាឃនៅភូមិក្បាលដំរី គេគ្រាន់តែសែនបាយសម្ល នំបញ្ចុក នំកប់ស្ករ នំអន្សមក្បុង និងសែនស្រូវប៉ុណ្ណោះ។ បន្ទាប់ពីសែនរួច ចាប់ពីពេលព្រលប់ទៅគេធ្វើពិធី

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

លៀងមេមត់ប្រចាំឆ្នាំនៅតាមក្រុមផ្ទះប្រហែលពីរបីកន្លែង រហូតម៉ោងទៀបភ្លឺចប់ក៏មាន។ សូមបញ្ជាក់ថា "មេមត់" ជាខ្មោចជួរចំបួរប្រចាំត្រកូល ហើយមាន "រូបស្នង" ដែលភាគច្រើនជាមនុស្សស្រី (រូបលេខ១០)។ "រូបស្នង" ដើរតួនាទីសំខាន់ក្នុងកិច្ចបញ្ជាន់មេមត់រកហេតុនៃវិបត្តិតូចធំ ដែលកើតឡើងផ្ទាល់ខ្លួន ឬក្នុងគ្រួសារ ឬតាមការពឹងពរពីអ្នកស្រុកជិតឆ្ងាយឱ្យជួយព្យាបាល ស្តោះផ្លុំ ឬរកទ្រព្យរបស់ដែលបាត់។



រូបលេខ១០ ពិធីលៀងមេមត់នៅភូមិក្បាលដំរី

អរិយធម៌ខ្មែរ KHMER CIVILIZATION

សង្ខេបខ្លីមកទម្លាប់ចាប់ត្រីនៅតាមត្រពាំងរួមក្នុងភូមិបង្កោង និងភូមិក្បាលដំរី នៃតំបន់អង្គរ ខេត្តសៀមរាប ដែលលើកមកនិយាយនេះ ស្តែងឱ្យឃើញពីសារៈសំខាន់នៃការរក្សាសម្បត្តិរួមគ្នាក្នុងសហគមន៍ និងចាត់ចែងដើម្បីរក្សាទំនៀមទម្លាប់តមក។ ចំពោះផលត្រីដែលទទួលបាន សម្រាប់បម្រើសេចក្តីត្រូវការរបស់អ្នកភូមិ ដែលខ្វាយខ្វល់ធ្វើកិច្ច ឬពិធីផ្សេងទៀតជាបន្ទាប់ដូចជាប្រគេនចង្ហាន់ព្រះសង្ឃ ទទួលភ្ញៀវជិតឆ្ងាយ និងកិច្ចការហូបចុកតាមគ្រួសារនារដូវបិទបញ្ចប់វដ្តធ្វើស្រែ។ សូមរម្លឹកថា បើមិនមានអ្វីប្រែប្រួលនោះទេ តាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តសៀមរាប ពិធីចាប់ត្រីត្រពាំងបឹង ក្នុងភូមិបង្កោង នឹងប្រព្រឹត្តទៅនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ខៀវ ច័ន្ទ

២០១៣-២០១៤, "សម្បត្តិរួមនៃសហគមន៍", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៩, ទំ.៣៨-៤៣, Friend of Khmer Culture, ភ្នំពេញ

ធាន់ សុភីនី, សោ ចន្ធា, តូច សុភៈ, ជា សំបូរ, អាន សីម៉ា, និង អ៊ូ គង្គា

២០២១, "កិច្ចពិធីនៅចុងវដ្តស្រូវៈ ករណីឡើងមាឃនៅភូមិបង្កោង", *ព្រះនគរ*, លេខ២៣, ទំ.១៨៣-១៩៦, អាជ្ញាធរជាតិអប្សរា, សៀមរាប

ហៀង ម៉ារ៉ា

២០២៣, *ប្រពៃណីចាប់ត្រីពាក់ព័ន្ធនឹងការបិទវគ្គស្រូវ*, សារណាបញ្ចប់បរិញ្ញាបត្រ, មហាវិទ្យាល័យបុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

អាំង ជូលាន

២០១២-២០១៣, "៣កើត មាឃធំ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៨, ទំ.៤៣-៤៨, Friend of Khmer Culture, ភ្នំពេញ

២០២០, *អាហារនៅជនបទអង្គរ*, យសោធរ, ភ្នំពេញ

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត